**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចាត់វិធានការចំពោះក្រុមហ៊ុន គ្លូរី នីតវែរ អិលធីឌី (GLORY KNITWEAR LTD.)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា ក្រុមហ៊ុន គ្លូរី នីតវែរ អិលធីឌី **(GLORY KNITWEAR LTD.)** ស្ថិតនៅផ្លូវជាតិលេខ៤ ភូមិកៅ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល មិនអនុវត្តតាមច្បាប់ស្តីពីការងារ ដោយបានគណនានិងទូទាត់ប្រាក់បំណាច់អតីតភាពការងារមិនត្រឹមត្រូវជូនបងប្អូនកម្មករនិយោជិត ដែលបង្កើតជាវិវាទការងារ កាលពីព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៥។

អនុលោមតាមច្បាប់ស្តីពីការងារ មាត្រា៨៩ថ្មី និងមាត្រា៣៨២ អធិការការងារបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ដោយបានធ្វើការផាកពិន័យជាប្រាក់ ចំពោះក្រុមហ៊ុននេះ ចំនួន ២០ ១៦០ ០០០ (ម្ភៃលានមួយរយហុកសិបពាន់គត់) រៀល ដើម្បីបង្ការជាដាច់ខាតនូវការអនុវត្តមិនត្រូវទាំងនេះ។

ទន្ទឹមនឹងនេះ ក្រសួងសូមក្រើនរំលឹកដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានផ្សេងទៀត ត្រូវទូទាត់នូវប្រាក់បំណាច់អតីតភាពការងារ និង/ឬប្រាក់អត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្នុងករណីមានការខកខានទូទាត់ ឬគណនាមិនបានត្រឹមត្រូវ ដែលនាំឱ្យមានវិវាទការងារ អធិការការងារនឹងចាត់វិធានការផាកពិន័យយ៉ាងតឹងរឹងតាមច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូមសាធារណជន និងបងប្អូនកម្មករនិយោជិតទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសៅរ៍ ៥រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៥